**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : .......................

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការដាក់ឲ្យអនុវត្តកម្មវិធី «ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់» ដើម្បីជួយគាំទ្រ គ្រួសារប្រជាពលរដ្ឋដែលមានកម្រិតជីវភាពទាប និងជួបប្រឈមនឹងការលំបាក ក្រោយការអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំ
## និង
## ការផ្តល់ជំនួយសង្គមជាសាច់ប្រាក់ សម្រាប់គ្រួសារដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ និង គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១

ដោយសារឥទ្ធិពលនៃការរាលដាលជំងឺកូវីដ-១៩ មានកម្រិតធំធេងរហូតឈានដល់ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និង ក្រុងតាខ្មៅនៃខេត្តកណ្តាល ព្រមទាំងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ, រាជរដ្ឋាភិបាលពិនិត្យឃើញពីភាពចាំបាច់ក្នុងការដាក់ចេញនូវជំនួយអន្តរាគមន៍សង្គម ដើម្បីជួយដោះស្រាយជីវភាពរបស់គ្រួសារប្រជាពលរដ្ឋមានកម្រិតជីវភាពទាប នៅក្នុងអំឡុងពេល និង មួយរយៈពេលខ្លីក្រោយដំណាក់កាលដ៏លំបាកនេះ ។ នៅក្នុងរយៈពេលអនុវត្តវិធានការបិទខ្ទប់, រាជរដ្ឋាភិបាលបាន និង កំពុងផ្តល់ **«ជំនួយសង្គ្រោះបន្ទាន់ក្នុងពេលបិទខ្ទប់»** ជាស្បៀងអាហារ រួមមាន អង្ករ, មី, ត្រីខកំប៉ុង, ទឹកត្រី និង/ឬ ទឹកស៊ីអ៊ីវ ជូនដល់គ្រួសារប្រជាពលរដ្ឋងាយរងគ្រោះ, ប្រជាពលរដ្ឋក្រីក្រ, កម្មករ-និយោជិត និង គ្រួសារប្រជាពលរដ្ឋផ្សេងទៀតដែលមានកម្រិតជីវភាពទាប និងជួបប្រឈមនឹងការលំបាក ហើយកំពុងរស់នៅក្នុងតំបន់ភូមិសាស្ត្របិទខ្ទប់ រួមជាមួយនឹងការដាក់ចេញនូវយន្តការសម្រួលឲ្យប្រជាពលរដ្ឋអាចទិញស្បៀងអាហារ និង ទំនិញជាគ្រឿងឧបភោគបរិភោគ ដោយសុវត្ថិភាពពីការឆ្លងជំងឺកូវីដ-១៩ និង តាមថ្លៃសមរម្យ ។

បន្ថែមលើនេះ, ក្នុងគោលបំណងជួយដោះស្រាយការលំបាករបស់គ្រួសារប្រជាពលរដ្ឋដែលមានកម្រិតជីវភាពទាប រស់នៅក្នុងភូមិសាស្ត្រនៃតំបន់ដែលត្រូវបានអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំ នៃរាជធានីភ្នំពេញ និង ក្រុងតាខ្មៅនៃខេត្តកណ្តាល ព្រមទាំងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ ក៏ដូចជាជួយដល់គ្រួសារដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ និង គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព នៅទូទាំងប្រទេស, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវកម្មវិធី **«ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់»** និង **«ជំនួយសង្គមជាសាច់ប្រាក់សម្រាប់គ្រួសារដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ និង គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១»** ដែលជាអន្តរាគមន៍ជំនួយសង្គមបន្ថែម ដោយរួមបញ្ចូល

ផងដែរ នូវគោលនយោបាយជួយឧបត្ថម្ភជាសាច់ប្រាក់សម្រាប់បង់ថ្លៃទឹកស្អាត និង អគ្គិសនី ក្នុងកម្រិតអប្បបរមា ដូចខាងក្រោម ៖

## ក. ការផ្តល់ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់

កម្មវិធី **«ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់»** នេះ ត្រូវបានដាក់ឲ្យអនុវត្តសម្រាប់ភូមិសាស្ត្រដែលទទួលរងនូវវិធានការនៃការបិទខ្ទប់ក្នុងលក្ខណៈទ្រង់ទ្រាយធំ រួមបញ្ចូលនូវ រាជធានីភ្នំពេញ, ក្រុងតាខ្មៅនៃខេត្ត កណ្ដាល និង ក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ និង ផ្តល់ជូនដល់គ្រួសារប្រជាពលរដ្ឋកម្ពុជាដែលមានជីវភាពលំបាក ទៅតាមទំហំគ្រួសារ ដែលត្រូវបានកំណត់អត្តសញ្ញាណច្បាស់លាស់ និង ត្រឹមត្រូវ ។

### (ទី១). ការកំណត់អត្តសញ្ញាណ

គ្រួសារប្រជាពលរដ្ឋគោលដៅ នៅរាជធានីភ្នំពេញ, ក្រុងតាខ្មៅ និងក្រុងព្រះសីហនុ ដែលទទួលបានការឧបត្ថម្ភនេះ រួមបញ្ចូលនូវៈ គ្រួសារអ្នកបើកបរ, កម្មករសំណង់, អ្នកលក់ដូរតាមផ្លូវ, បុគ្គលិកលក់ដូរតាមផ្សារ, អ្នករើសសំរាម និង អ្នកធ្វើការផ្នែកសេវាកម្សាន្ត ជាដើម ដែលនឹងទទួលបានការវាយតម្លៃដោយអាជ្ញាធរមូលដ្ឋាន ដោយមានការគាំទ្រពីកម្លាំងស្ម័គ្រចិត្ត ក្រោមការចាត់ចែង និង សម្របសម្រួលដោយក្រសួងផែនការ តាមរយៈការធ្វើកិច្ចសម្ភាសន៍តាមទូរស័ព្ទ សម្រាប់តំបន់ដែលមិនទាន់មានសុវត្ថិភាពពីការឆ្លងជំងឺកូវីដ-១៩ ឬ តាមរយៈការធ្វើកិច្ចសម្ភាសន៍ផ្ទាល់មុខ សម្រាប់តំបន់ដែលមានសុវត្ថិភាពពីការឆ្លងជំងឺកូវីដ-១៩ ។

### (ទី២). របបឧបត្ថម្ភ

គ្រួសារប្រជាពលរដ្ឋគោលដៅ នៅរាជធានីភ្នំពេញ, ក្រុងតាខ្មៅ និងក្រុងព្រះសីហនុ ដែលត្រូវបានកំណត់អត្តសញ្ញាណ នឹងទទួលបានរបបឧបត្ថម្ភជាសាច់ប្រាក់សម្រាប់ជួយសម្រាលបន្ទុកថ្លៃស្បៀងអាហារ និង សម្រាប់ជួយបង់ថ្លៃទឹកស្អាត និង អគ្គិសនី ក្នុងកម្រិតអប្បបរមា សរុបមួយលើកគត់ តាមរយៈធនាគារវីង (Wing) ទៅតាមទំហំគ្រួសារ ដូចខាងក្រោម៖

| ទំហំគ្រួសារ | ថ្លៃស្បៀងអាហារ (រៀល) | ថ្លៃទឹកស្អាត ២ ខែ (រៀល) | ថ្លៃអគ្គិសនី ២ ខែ (រៀល) | សរុបជាទឹកប្រាក់ (រៀល) |
|---|---|---|---|---|
| ១ នាក់ | ១០០ ០០០ ៛ | ៧ម³/ខែ×២×១២៥០៛≈ ១៨ ០០០ ៛ | ៤០kWh/ខែ×២×៤៨០៛≈ ៣៨ ០០០ ៛ | ១៥៦ ០០០ ៛ |
| ២ - ៣ នាក់ | ១១៣ ៥០០ ៛ | ១៨ម³/ខែ×២×១២៥០៛≈ ៤៤ ៨០០ ៛ | ៧០kWh/ខែ×២×៦១០៛≈ ៨៥ ៤០០ ៛ | ២៤៣ ៧០០ ៛ |
| ៤ នាក់ឡើង | ១២៧ ០០០ ៛ | ២៥ម³/ខែ×២×១២៥០៛≈ ៦២ ០០០ ៛ | ១០០kWh/ខែ×២×៦១០៛≈ ១២២ ០០០ ៛ | ៣១១ ០០០ ៛ |

កម្មករ-និយោជិតបម្រើការនៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរ សម្លៀកបំពាក់, ស្បែកជើង និង កាបូប នៅក្នុងតំបន់បិទខ្ទប់ដូចបានកំណត់ខាងលើ នឹងទទួលបានការឧបត្ថម្ភ **មួយលើកគត់ ចំនួន ១៦ ម៉ឺនរៀល/ម្នាក់** ដែលនឹងត្រូវបានផ្តល់ជូន តាមរយៈយន្តការមានស្រាប់ ដែលក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងអនុវត្តផ្តល់ជំនួយគាំទ្រសម្រាប់ករណីព្យួរការងារបណ្តោះអាសន្ន ។

គ្រួសារប្រជាពលរដ្ឋដែលមានបណ្ណសមធម៌ ប្រភេទ **«ក្រ-១»** និង **«ក្រ-២»** នៅក្នុងតំបន់បិទខ្ទប់ដូចបានកំណត់ខាងលើ និងដែលកំពុងបន្តទទួលបាននូវជំនួយឧបត្ថម្ភជាសាច់ប្រាក់សម្រាប់ទ្រទ្រង់ជីវភាពពីរដ្ឋជារៀងរាល់ខែ គឺនឹងមិនទទួលបាននូវរបបជំនួយឧបត្ថម្ភបន្ថែមទៀតទេ។

## ២. ការផ្តល់ជំនួយសង្គមសម្រាប់គ្រួសារដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ និង គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព នៅក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១

ទន្ទឹមនឹងការជួយឧបត្ថម្ភប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បិទខ្ទប់ទ្រង់ទ្រាយធំខាងលើ, រាជរដ្ឋាភិបាលក៏សម្រេចផ្តល់ជូនផងដែរ នូវការឧបត្ថម្ភជាសាច់ប្រាក់សម្រាប់គ្រួសារដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ និង គ្រួសារដែលមានឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព នៅក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ឆ្នាំ ២០២១ នៅទូទាំងប្រទេស ដូចខាងក្រោម៖

- **សម្រាប់គ្រួសារដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩៖** ផ្តល់ជូនការឧបត្ថម្ភជាសាច់ប្រាក់ចំនួន ៣០០.០០០ (សាមសិបម៉ឺន) រៀល និងបូកបន្ថែមនូវការឧបត្ថម្ភជាសាច់ប្រាក់សម្រាប់ជួយបង់ថ្លៃអគ្គិសនី និងទឹកស្អាត សម្រាប់រយៈពេល ៥ ខែ ស្របតាមមូលដ្ឋានគណនាដែលត្រូវបានកំណត់សម្រាប់ **«ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់»** ខាងលើ ។ ការឧបត្ថម្ភនេះផ្តល់ជូនបន្ថែមពីលើជំនួយសង្គមជាធរមានទាំងឡាយដែលគ្រួសារប្រជាពលរដ្ឋគោលដៅទទួលបាន និង ត្រូវបានបើកផ្តល់ជូនជាសាច់ប្រាក់សរុប តែមួយលើក តាមរយៈធនាគារវីង ។
- **សម្រាប់គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព៖**
  - គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព ស្ថិតនៅក្នុងភូមិសាស្ត្រក្រៅពីរាជធានីភ្នំពេញ, ក្រុងតាខ្មៅ និងក្រុងព្រះសីហនុ នឹងទទួលបានកញ្ចប់សាច់ប្រាក់ឧបត្ថម្ភសរុប តាមទំហំគ្រួសារ ដូចគ្នានឹងការឧបត្ថម្ភជាសាច់ប្រាក់ជូនដល់គ្រួសារប្រជាពលរដ្ឋគោលដៅ ដែលស្ថិតនៅក្រោមកម្មវិធី **«ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់»** ដែរ ។
  - កម្មករ-និយោជិតឆ្លងជំងឺកូវីដ-១៩ ដែលបម្រើការនៅតាមរោងចក្រ-សហគ្រាសនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់, ស្បែកជើង និងកាបូប និងដែលស្ថិតនៅក្នុងភូមិសាស្ត្រក្រៅពីរាជធានីភ្នំពេញ, ក្រុងតាខ្មៅ និងក្រុងព្រះសីហនុ នឹងទទួលបានកញ្ចប់សាច់ប្រាក់ឧបត្ថម្ភសរុប **ចំនួន ១៦ ម៉ឺនរៀល/ម្នាក់** ដែលនឹងត្រូវបើកផ្តល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។
  - គ្រួសារប្រជាពលរដ្ឋដែលមានបណ្ណសមធម៌ប្រភេទ **«ក្រ-១»** និង **«ក្រ-២»** ដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងដែលកំពុងបន្តទទួលបាននូវជំនួយឧបត្ថម្ភជាសាច់ប្រាក់សម្រាប់ទ្រទ្រង់ជីវភាពពីរដ្ឋជារៀងរាល់ខែ នឹងមិនទទួលបាននូវរបបជំនួយឧបត្ថម្ភថែមទៀតទេ ។
  - គ្រួសារដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព ក៏ដូចជាកម្មករ-និយោជិតឆ្លងជំងឺកូវីដ-១៩ ដែលបម្រើការនៅតាមរោងចក្រនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់, ស្បែកជើង និងកាបូប នៅក្នុងរាជធានីភ្នំពេញ, ក្រុងតាខ្មៅ និងក្រុងព្រះសីហនុ នឹងមិនទទួលបាននូវរបបជំនួយឧបត្ថម្ភថែមទៀតទេ ព្រោះរដ្ឋបានផ្តល់ជំនួយឧបត្ថម្ភជាសាច់ប្រាក់ក្រោមកម្មវិធី **«ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់»** ជូនរួចហើយ ។

យន្តការ, នីតិវិធី និង កាលបរិច្ឆេទនៃការបើកផ្តល់អន្តរាគមន៍ជំនួយសង្គមខាងលើនេះ នឹងត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ។

*ថ្ងៃអង្គារ ១៥ រោច ខែ ពិសាខ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២១*